**EMPLOYMENT DEVELOPMENT DEPARTMENT**
**PO Box 2530**
**Rancho Cordova, CA 95741-2530**

Employment Development Department
State of California

**លេខទូរស័ព្ទមិនអស់លុយរបស់៖ 1-866-401-2849**

# ឯកសារអាចទទួលបាន សម្រាប់ការផ្ទៀងផ្ទាត់អត្តសញ្ញាណ

**(ដាក់បញ្ជូលសំណៅ លើកលែងតែបានកំណត់ប្រាប់)**

អ្នកត្រូវទេផ្តល់ **មួយ** ឯកសារពី ***"រូបថតអត្តសញ្ញាណ"*** ផ្នែក ***និង*** យ៉ាងហោចណាស់ **មួយ** នៃឯកសារពី **"ឯកសារ អត្តសញ្ញាណដទៃទៀត"** ផ្នែក ។ ឯកសារទាំងអស់ដែលបានដាក់បញ្ជូល គួរតែត្រូវបានចម្លងលើ **ក្រដាសទំហំ 8 ½ x 11 អ៊ីញ** ហើយត្រូវបញ្ជូលលេខសន្តិសុខសង្គមរបស់អ្នក (SSN) នៅលើទំព័រនីមួយៗ ។

## រូបថតអត្តសញ្ញាណ

ផ្តល់ ច្បាប់ចម្លង ច្បាស់លាស់ និងអាចអានបាននៃ **មួយ** នៃឯកសារខាងក្រោមដែលចេញដោយក្រសួងរដ្ឋ មូលដ្ឋាន ឬសហព័ន្ធដែលមានឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងរូបថតរបស់អ្នក ៖

- ប័ណ្ណបើកឡាន ឬ ប័ណ្ណអែឌី
- ប័ណ្ណឆ្លងដែនសហរដ្ឋអាមេរិក **ឬ** កាតប័ណ្ណឆ្លងដែនសហរដ្ឋអាមេរិក
- ប័ណ្ណឆ្លងដែនបរទេស
- ប័ណ្ណអែឌីទាហាន (ខាងមុខនិងខាងក្រោយ)
- ប័ណ្ណអែឌីរបស់ជនពឹងផ្អែកទាហាន (ខាងមុខនិងខាងក្រោយ)
- ឯកសារអនុញ្ញាតការងារដែលចេញដោយសេវាសញ្ជាតិនិងអន្តោប្រវេសន៍សហរដ្ឋអាមេរិក (USCIS) *(ទម្រង់ USCIS I-766)*
- វិញ្ញាបនបត្រនៃភាពជាពលរដ្ឋ *(ទម្រង់ USCIS N-600)*
- វិញ្ញាបនបត្រនៃភាពជាពលរដ្ឋ *(ទម្រង់ USCIS N-550)*
- ប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ ឬប័ណ្ណចុះឈ្មោះជនបរទេស *(ទម្រង់ USCIS I-551)*

## ឯកសារអត្តសញ្ញាណដទៃទៀត

ផ្តល់ច្បាប់ចម្លងច្បាស់លាស់ និងអាចអានបាន ឬឯកសារដើម (ដូចបានបញ្ជាក់) យ៉ាងហោចណាស់ **មួយ** ខាងក្រោម៖

**ទិន្នន័យការងារ**

- ច្បាប់ចម្លងនៃ W-2 យ៉ាងហោចណាស់មួយដែលបានចេញឱ្យអ្នកសម្រាប់ឆ្នាំមុន; **ឬ**
- ច្បាប់ចម្លងនៃដើមមូលប្បទានប័ត្រ ដែលបានបោះពុម្ពជាមុនយ៉ាងហោចណាស់មួយច្បាប់ ឬសេចក្តីថ្លែងការណ៍ទូទាត់ដែលចេញឱ្យអ្នកដោយនិយោជករបស់អ្នកក្នុងរយៈពេលដប់ពីរខែមុនកាលបរិច្ឆេទដែលការទាមទាររបស់អ្នកត្រូវបានដាក់ជាលើកដំបូង និងមាន ៖
    - o ឈ្មោះរបស់អ្នក (ឬឈ្មោះដំបូង) និងនាមត្រកូលរបស់អ្នក**និង** SSN (យ៉ាងហោចណាស់ 4 ខ្ទង់ចុងក្រោយ) ឬលេខអត្តសញ្ញាណបុគ្គលិករបស់អ្នក **និង** ឈ្មោះនិយោជក **នឹង** កាលបរិច្ឆេទនៃរយៈពេលបង់ប្រាក់ ឬកាលបរិច្ឆេទដែលដើមសែក ឬរបាយការណ៍ទូទាត់ត្រូវបានចេញ។

**ឬ**

**ការផ្ទៀងផ្ទាត់អាសយដ្ឋាន** (បង្ហាញ**ឈ្មោះ** របស់អ្នក និង**លំនៅដ្ឋាន** បច្ចុប្បន្ន)

- ច្បាប់ចម្លងនៃវិក្កយបត្រឧបករណ៍ប្រើប្រាស់ដែលមិនផ្លាស់ប្តូរ (អគ្គិសនី ឧស្ម័ន សំរាម ទឹក ឬលូ) វិក័យប័ត្រ ទូរទស្សន៍ខ្សែកាប វិក្កយបត្រទូរស័ព្ទ របាយការណ៍ ធនាគារ វិក្កយបត្រពន្ធលើអចលនទ្រព្យ របាយការណ៍បញ្ចាំ ឬ កិច្ចព្រមព្រៀង ជួល/ជួលបច្ចុប្បន្ន និងពេញលេញ។**ឬ**
- ច្បាប់ចម្លងនៃការផ្ទៀងផ្ទាត់ការចុះឈ្មោះជាអ្នកជួល/អ្នកប្រើប្រាស់ដែលមានការអនុញ្ញាតពីប្រអប់ ប្រៃសណីយ៍ ឬប្រអប់សំបុត្រឯកជន ។

**ឬ**

**ការផ្ទៀងផ្ទាត់ លេខសន្តិសុខសង្គម** *(កាតសន្តិសុខ សង្គម នឹងមិនបំពេញតាមតម្រូវការនេះទេ)*។

- ច្បាប់ចម្លងពេញលេញ (ទំព័រ 1, 2, និង 3) នៃ ***សេចក្តីថ្លែងការណ៍សន្តិសុខសង្គម*** របស់អ្នកមាននៅលើអ៊ីនធឺណិត នៅ **socialsecurity.gov/myaccount**,**ឬ**
- សេចក្តីជូនដំណឹងដើមចំពោះភាគីទីបីនៃការចាត់តាំងលេខសន្តិសុខសង្គម *(SSA Form 7028)*; **ឬ**
- របាយការណ៍ដើមនៃព័ត៌មានអត្ថប្រយោជន៍សន្តិសុខសង្គមសម្ងាត់ *(SSA Form 2458).*

**ឬ**

**ការផ្ទៀងផ្ទាត់កាលបរិច្ឆេទកំណើត**

- ច្បាប់ចម្លងសំបុត្រកំណើតផ្លូវការដែលចេញដោយទីភ្នាក់ងារក្នុងស្រុក រដ្ឋ ឬសហព័ន្ធ ឬរដ្ឋាភិបាលបរទេស ឬលិខិតបញ្ជាក់ផ្លូវការផ្សេងទៀតអំពីកំណើតរបស់អ្នក ។ សំបុត្រកំណើតដែលសម្គាល់ "ព័ត៌មាន មិនមែនជាឯកសារត្រឹមត្រូវក្នុងការកំណត់អត្តសញ្ញាណ" មិនអាចផ្ទៀងផ្ទាត់ដែលអាចទទួលយកបានទេ ។ ការបកប្រែជាផ្លូវការនៃសំបុត្រកំណើតតែម្នាក់ឯង មិនអាចទទួលយកបាននូវកាលបរិច្ឆេទនៃការផ្ទៀងផ្ទាត់កំណើតនោះទេ ។ សំបុត្រកំណើតផ្លូវការត្រូវតែភ្ជាប់ជាមួយការបកប្រែជាផ្លូវការ ។